ក ស ក
គណៈកម្មាធិការ
សហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

ទស្សនវិស័យ: ការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសកម្ពុជា
Vision: Sustainable development for Cambodia

លេខ: ០២៤.៣ CCC/២០១៥

សូមគោរពជូន

ឯកឧត្តម ឈាង ឫន ប្រធានគណៈកម្មការទី៥
កិច្ចការបរទេស សហប្រតិបត្តិការអន្តរជាត ឃោសនាការ និងព័ត៌មាន
នៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា

កម្មវត្ថុ: សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ **ឯកឧត្តម** ដែលបានអនុញ្ញាតឲ្យយើងខ្ញុំតំណាងអង្គការសង្គមស៊ីវិលចូលជួបពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាលកាលពីថ្ងៃទី១៩ ខែ ឧសភា ឆ្នាំ២០១៥។

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ជាអង្គការសមាជិកភាពដែលមានអង្គការជាតិ និងអន្តរជាតិចំនួនជាង១៦០ដែលកំពុងប្រតិបត្តិការនៅកម្ពុជា សូមអនុញ្ញាតសំដែងអំណរគុណ និងអំណរសាទរយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម** និងរដ្ឋសភាដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អនិងបន្តការគាំទ្រដល់សមាគម អង្គការមិនមែនរដ្ឋាភិបាល ដើម្បីឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលអាចផ្តល់ការគាំទ្រដល់ការអភិវឌ្ឍប្រទេសកម្ពុជាប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ។

យោងតាមស្មារតីនេះ យើងខ្ញុំសូមគោរពអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម** ដើម្បីចូលជួបពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាមួយ **ឯកឧត្តម** នៅពេលសេចក្តីព្រាងច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាលមកដល់រដ្ឋសភាជាតិ។ កាយវិការគាំទ្រ និងសហការរបស់ **ឯកឧត្តម** បញ្ជាក់ឲ្យយើញថា អង្គការសង្គមស៊ីវិលគឺជាដៃគូរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍប្រទេសកម្ពុជា។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា **ឯកឧត្តម** នឹងផ្តល់កិត្តិយសទទួលយកសំណើរបស់យើងខ្ញុំដោយសេចក្តីអនុគ្រោះ។

អ្នកស្រី **ស៊ិន ពុទ្ធារី** តំណាងក្រុមការងាររៀបចំកម្មវិធី (ទូរស័ព្ទលេខ ០១២ ៧៦៩៨៣៦) នឹងបន្តទំនាក់ទំនងជាមួយអត្តលេខាធិការដ្ឋានរដ្ឋសភាអំពីសំណើនេះ។

សូមគោរពជូនពរ **ឯកឧត្តម** មានសុខភាពល្អ និងសូម **ឯកឧត្តម** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៦..... ខែ ឧសភា ឆ្នាំ ២០១៥

តំណាងអង្គការសង្គមស៊ីវិល

ឃន ឫនថុន

ចម្លងជូនៈ
១.អត្តលេខាធិការដ្ឋានរដ្ឋសភា
២.ប្រធានគណៈកម្មការទី៥ កិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃរដ្ឋសភា

www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability Transparency
GPP
Symbol of Trust